ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ: ១៤៥/២១ ជ.ល.ក

**សូមគោរពជូន**
**ឯកឧត្តម ប៊ុន ហុន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាប្រធានក្រុម**
**ការងារទទួលបន្ទុកសរសេររបាយការណ៍សិទ្ធិមនុស្ស**
**ពាក់ព័ន្ធសមត្ថកិច្ច ក្រសួងមហាផ្ទៃ**

**កម្មវត្ថុ**: របាយការណ៍ឆ្លើយតបលិខិតរបស់UNITED NATIONS CAMBODIA ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០២១ ស្តីពីConcerns related to the detention and treatment of "entertainment workers" and "people in street" during the COVID-19 pandemic.

**យោង**: - បំណារ **ឯកឧត្តម សក់ សេដ្ឋា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១។
- របាយការណ៍របស់ អភិបាល នៃគណៈអភិបាល និងជាប្រធាន គ.រ.ប.ជ រាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើក្នុងនាមនាងខ្ញុំជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងជាសមាជិកក្រុមការងារ សរសេររបាយការណ៍សិទ្ធិមនុស្សរបស់ក្រសួងមហាផ្ទៃ មានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តម រដ្ឋលេខាធិការ** មេត្តាជ្រាបថា: នាងខ្ញុំបានដឹកនាំក្រុមការងារពិនិត្យរួចហើយនូវឯកសារ ដែលបានបញ្ជូនមកក្រសួងមហាផ្ទៃដោយ UNITED NATIONS CAMBODIA ។

ពាក់ព័ន្ធខ្លឹមសារដែលមាននៅក្នុងប្រធានបទខាងលើ និងយោងតាមរបាយការណ៍របស់អភិបាល នៃគណៈអភិបាល និងជាប្រធាន គ.រ.ប.ជ រាជធានីភ្នំពេញនៅក្នុងព្រឹត្តិការណ៍ "សហគមន៍ ២០កុម្ភៈ" ឆ្នាំ ២០២១ បានបញ្ជាក់ថា រដ្ឋបាលរាជធានីភ្នំពេញ បានដាក់ចេញនូវវិធានការនានាសំដៅបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ "សហគមន៍ ២០កុម្ភៈ ២០២១"នៅរាជធានីភ្នំពេញ ដោយផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងផ្អាករាល់ការជួបជុំ ឬប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជននៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មានដូចជា៖ ការផ្អាកគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន អាជីវកម្មក្លឹបកម្សាន្តគ្រប់ប្រភេទ ជាអាទិ៍ ទីតាំងខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀហ្គាឌិន កាស៊ីណូ រមណីយដ្ឋាន សារមន្ទីរ សួនកុមារ និងសួនកម្សាន្តនានា អាជីវកម្មម៉ាស្សា សូណា ស្ទីមគ្រប់ប្រភេទ ហាងលក់ និងសេពគ្រឿងស្រវឹងគ្រប់ប្រភេទ រោងភាពយន្ត រោងសម្តែងសិល្បៈ ក្លឹបហាត់ប្រាណ និងមជ្ឈមណ្ឌលកីឡាគ្រប់ប្រភេទ ពិសេសរហូតដល់បិទរាជធានីភ្នំពេញ ពុំឱ្យមានចរាចរណ៍ទៀតផង។

ដោយឡែកចំពោះមុខរបរបម្រើសេវាភេទ របស់នារីរកស៊ីផ្លូវភេទ និងជនអនាថាតាមដងផ្លូវ ក៏ត្រូវបានចាត់ទុកថា ជាមុខសញ្ញារងគ្រោះ ក្នុងការឆ្លងនិងចម្លងជំងឺកូវីដ-១៩ ផងដែរ ទើបរដ្ឋបាលរាជធានីភ្នំពេញណែនាំឱ្យអាជ្ញាធរខណ្ឌ ចុះរៀបចំសណ្តាប់ធ្នាប់ និងប្រមូលពួកគាត់ឲ្យទៅនៅមណ្ឌលព្រៃស្តីជាបណ្តោះអាសន្ន។ ជាក់ស្តែងរដ្ឋបាលខណ្ឌដូនពេញ បានធ្វើការរៀបចំសណ្តាប់ធ្នាប់ និងសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ យកនារីដែលរកស៊ីផ្លូវភេទ និងជន

អនាថាមួយចំនួនទៅធ្វើតេស្តស្វែងរកជំងឺកូវីដ-១៩នៅវិទ្យាល័យ ហ៊ុនសែនប៊ុនរ៉ានី វត្តភ្នំ។ ក្រោយពីចប់ការធ្វើចត្តាឡីស័ក រដ្ឋបាលរាជធានីភ្នំពេញបានបញ្ជូនពួកគេទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ដើម្បីទទួលយកសេវាដែលផ្តល់ដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ រៀបចំនីតិវិធីក្នុងការបញ្ជូនពួកគាត់ទៅក្រុមគ្រួសារឬទៅអង្គការដៃគូ ដែលនេះជាសកម្មភាពមនុស្សធម៌មួយ ក្នុងការការពារអាយុជីវិតប្រជាពលរដ្ឋ ដោយឥតរើសអើង ដែលរួមទាំងអ្នករកស៊ីបម្រើសេវាផ្លូវភេទ និងជនអនាថាគ្មានទីពឹង ដើម្បីឲ្យចៀសផុតពីជំងឺកូវីដ-១៩។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទារាជធានីភ្នំពេញ បានកំពុងដំណើរការទទួលសង្គ្រោះជនរងគ្រោះ និងជនងាយរងគ្រោះ ក្នុងនោះជនវ័យចាស់ជរាគ្មានទីពឹង ទុរគតជន ជនអនាថា ជនវិបល្លាសស្មារតី ជនពិការគ្មានទីពឹង អ្នកសុំទាន ស្ត្រីរកស៊ីផ្លូវភេទគ្មានសុវត្ថិភាព និងស្ត្រីរងគ្រោះដោយអំពើជួញដូរផ្លូវភេទក្នុងរាជធានីភ្នំពេញ សរុបចំនួន ៣៣៧នាក់ (ស្រី ១៤១នាក់) ដើម្បីផ្តល់ការហូបចុក ស្នាក់នៅអប់រំស្តារនីតិសម្បទា និងស្វែងរកគ្រួសារដែលពួកគេបានធ្វើចំណាកស្រុកប្រថុយប្រថានធ្វើសកម្មភាពលើមុខរបរប្រកបដោយហានិភ័យខ្ពស់ក្នុងទីប្រជុំជនរាជធានីភ្នំពេញ ដែលជាទីកន្លែងពោរពេញទៅដោយការអភិវឌ្ឍ និងស៊ីវិល័យស្រស់ឆើតឆាយ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បាននិងកំពុងអនុវត្តដំណើរការមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ) ស្របតាមការដឹកនាំពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមការណែនាំលក្ខណៈបច្ចេកទេសត្រឹមត្រូវ បទដ្ឋានថែទាំជនរងគ្រោះ និងជនងាយរងគ្រោះ ទទួលបានការគាំទ្រសកម្មភាពយ៉ាងពេញលេញពីរដ្ឋបាលរាជធានីភ្នំពេញ អំពីនីតិវិធីការទទួល និងផ្តល់សេវាជូនជនរងគ្រោះ និងជនងាយរងគ្រោះក្នុងមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ)។

មជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ ស្ថិតក្នុងភូមិស្រែជំរៅ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានអគារទីចាត់ការ០១ខ្នង អគារពិគ្រោះយោបល់០១ខ្នង ប៉ុស្តិ៍សុខភាព០១ខ្នង អគារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ០១ខ្នង អគារស្នាក់នៅ របស់ជនរងគ្រោះ និងជនងាយរងគ្រោះ ០៣ខ្នង (អគារបុរស ០២ខ្នង និងផ្នែកនារី ០១ខ្នង) សាលប្រជុំ០១ អគាររោងបាយ និងដាំបាយ០១ខ្នង។

\+ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បានផ្តល់សេវាចាំបាច់មួយចំនួនដែលផ្តល់អត្ថប្រយោជន៍ជូនជនរងគ្រោះ និងជនងាយរងគ្រោះរួមមាន៖

- ទទួលសង្គ្រោះជនរងគ្រោះ និងជនងាយរងគ្រោះពីតាមបណ្តាខណ្ឌ ដែលបានបញ្ជូនមកដោយផ្តល់ការស្នាក់នៅ ទទួលអាហារហូបចុក០៣ពេលក្នុង០១ថ្ងៃ បង្អែម០១ដងក្នុង០១សប្តាហ៍
- បែងចែកប្រភេទជនរងគ្រោះ និងជនងាយរងគ្រោះប្រុស-ស្រី (ដាក់ដាច់ដោយឡែកពីគ្នា)
- ពិគ្រោះយោបល់ស្វែងរកគ្រួសារសាច់ញាតិ ដើម្បីប៉ាន់ប្រមាណធ្វើផែនការសមាហរណកម្មទៅក្រុមគ្រួសារវិញ និងថតរូបបំពេញឯកសារ កំណត់អត្តសញ្ញាណ បញ្ចូលទិន្នន័យជនរងគ្រោះ ទៅតាមទម្រង់នីមួយៗ
- អប់រំ ផ្សព្វផ្សាយ ដល់ជនរងគ្រោះ និងជនងាយរងគ្រោះ អំពីផលប៉ះពាល់បញ្ហាប្រឈមនានាដែលបណ្តាលមកពីមុខរបរគ្មានសុវត្ថិភាព

\+ ចំពោះករណីអ្នកសុំទាន និងស្ត្រីរកស៊ីផ្លូវភេទ គឺមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញបាន៖

- បញ្ជូនជនរងគ្រោះ ទៅព្យាបាលតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋនានា នៅពេលមានជំងឺធ្ងន់ធ្ងរ និងបន្ទាន់
- ផ្តល់កម្មវិធីហាត់ប្រាណដើម្បីសុខភាព កម្មវិធីសូត្រធម៌អប់រំផ្លូវចិត្ត និងកម្មវិធីបណ្តុះបណ្តាលជំនាញ
- មានបុគ្គលិកប្រចាំការដើម្បីមើលថែ និងបញ្ជូនជនរងគ្រោះ និងជនងាយរងគ្រោះ ទៅមន្ទីរពេទ្យនៅពេលដែលមានជំងឺ និងការយកចិត្តទុកដាក់ ផ្គត់ផ្គង់ម្ហូបអាហារប្រកបដោយគុណភាព
- យកចិត្តទុកដាក់ និងសហការជាមួយគ្រូពេទ្យផ្នែកព្យាបាលជំងឺក្នុងការព្យាបាលដល់ជនរងគ្រោះ និងជនងាយរងគ្រោះ តាមបន្ទប់ស្នាក់នៅ (គ្រូពេទ្យបញ្ជូនមកពីមន្ទីរសុខាភិបាលរាជធានីភ្នំពេញ)
- មានកម្មវិធីសួរសុខទុក្ខពីសំណាក់សាច់ញាតិជនរងគ្រោះ និងជនងាយរងគ្រោះ បានស្វែងរកឃើញ
- រៀបចំផែនការជំនាញពិតប្រាកដ និងបញ្ជូនបន្តទៅរកសេវា ចាំបាច់ពីអង្គការដៃគូអភិវឌ្ឍន៍ ដើម្បីពួកគេទទួលបាននូវអត្ថប្រយោជន៍ខ្ពស់ និងធ្វើសមាហរណដល់ជនរងគ្រោះ និងជនងាយរងគ្រោះ ដែលបានស្វែងរកបងប្អូនឃើញ អប់រំបញ្ជូនពួកគេឱ្យត្រឡប់ទៅក្រុមគ្រួសារ និងសហគមន៍វិញ
- សហការជាមួយមន្ទីរស.អ.យ ដើម្បីសមាហរណកម្មជនរងគ្រោះ ឱ្យត្រឡប់ទៅតាមបណ្តាខេត្តនានាវិញ (ករណីជនរងគ្រោះ និងជនងាយរងគ្រោះមកពីតាមបណ្តាខេត្ត)។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារទទួលបន្ទុកសរសេររបាយការណ៍សិទ្ធិមនុស្ស** មេត្តាជ្រាបជារបាយការណ៍ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ៕

ថ្ងៃ........................ខែ.................. ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី...២១...ខែ...កញ្ញា...ឆ្នាំ ២០២១

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេង.ម៉ុណ្ណ សំខាន់

<u>ចម្លងជូន៖</u>

- *លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ (ជូនជ្រាប)*
- *ឯកសារកាលប្បវត្តិ*